ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំ **វណ្ណ ម៉ូលីវណ្ណ** ឧត្តមប្រឹក្សា ផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

**សូមជំរាបមក**

លោក **ឆាំង យុ** នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានទទួលរួចហើយ នូវលិខិតរបស់លោក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ដែលបាន

១- សាកសួរអំពីដំណើរការវិវឌ្ឍន៍គម្រោងរបស់ខ្ញុំ **វណ្ណ ម៉ូលីវណ្ណ** (WWW-vannmoLyvannproject.org) ដែលបានដំណើរការកន្លងមក ។

២-អំពីដំណើរការ វិវឌ្ឍន៍ ការសាងសង់វិទ្យាស្ថានស្លឹករឹត របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

៣- ការមកដល់របស់ក្រុមស្ថាបត្យករ ហ្សាហា ហាឌីត (WWW-Zaha-hadid.com) ក្នុង ខែមិនា ឆ្នាំ ២០១៤ ហើយមានបំណងអញ្ជើញ ខ្ញុំចូលរួមក្នុង ការសាងសង់វិទ្យាស្ថានស្លឹករឹតនេះ ។

ខ្ញុំសូមអរគុណ ដ៏ធំធេង និងជ្រាលជ្រៅបំផុត ចំពោះសំណួរទាំងអស់នេះ ព្រោះជាកិត្តិយសធំណាស់ដែលលោកបានផ្តល់មករូបខ្ញុំ ។

ប៉ុន្តែខ្ញុំពុំអាចនឹងឆ្លើយតបតាមសំណើរលោកបានឡើយ ដោយខ្ញុំមានជន្មាយុចាស់ណាស់ហើយ ហើយស្មារតី សុខភាពក៏មិនល្អផង ខ្ញុំពុំអាចនឹងអង្គុយយូរបានឡើយហើយធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយដោយរទេះ ។

អាស្រ័យដូច បានជំរាបជូនខាងលើ សូមលោកប្រធាន មជ្ឈមណ្ឌលឯកសារកម្ពុជានិងសហការី ព្រមទាំងក្រុមស្ថាបត្យករ (WWW.Zaha-hadid.com) ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពង់ពីខ្ញុំ ។

ធ្វើនៅភ្នំពេញថ្ងៃទី...១៨...ខែ កុម្ភៈ ឆ្នាំ ២០១៤

**វណ្ណម៉ូលី វណ្ណ**